ជោគជ័យ
ហ្វាយនែន

ជម្រើសប្រសើរបំផុតដើម្បីជោគជ័យ

# របាយការណ៍ប្រចាំឆ្នាំ ២០១៩




# មាតិកា

សាររបស់ប្រធានក្រុមប្រឹក្សាភិបាល.......... ៤
សាររបស់អគ្គនាយក.......... ៦

**អំពីជោគជ័យ**

- ប្រវត្តិសង្ខេបរបស់ជោគជ័យ.......... ៩
- តារាងសង្ខេបលទ្ធផលឆ្នាំ២០១៩.......... ៩
- ចក្ខុវិស័យ បេសកកម្ម ទស្សនៈវិស័យ និងវប្បធម៌.......... ១០
- ភាគទុនិក.......... ១២
- រចនាសម្ព័ន្ធគ្រឹះស្ថាន.......... ១៥
- ក្រុមប្រឹក្សាភិបាល.......... ១៦
- គណៈគ្រប់គ្រង.......... ១៧
- ប្រភពទុនវិនិយោគ និងដៃគូសហការ.......... ២៣

**សមិទ្ធិផលអាជីវកម្មឆ្នាំ២០១៩**

- ផលិតផលកម្ចី.......... ២៥
- ការិយាល័យសាខា.......... ៣០
- ព្រឹត្តិការណ៍សង្ខេបឆ្នាំ២០១៩.......... ៣២
- ភាពជោគជ័យរបស់អតិថិជន.......... ៣៦

**របាយការណ៍ហិរញ្ញវត្ថុ**

- របាយការណ៍របស់ក្រុមប្រឹក្សាភិបាល.......... ៣៩
- របាយការណ៍របស់សវនករឯករាជ្យ.......... ៤២
- របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ.......... ៤៧
- របាយការណ៍ចំណេញ ឬខាត និងចំណូលពេញលេញផ្សេងៗ.......... ៤៩
- របាយការណ៍បម្រែបម្រួលមូលធន.......... ៥០
- របាយការណ៍លំហូរសាច់ប្រាក់.......... ៥៤

# សាររបស់លោកប្រធានក្រុមប្រឹក្សាភិបាល

ទទួលបានអនុភាពអាជីវកម្មដ៏មានឥទ្ធិពល និងស្វាហាប់ពីប្រទេសកូរ៉េខាងត្បូង ជោគជ័យ ហ្វាយនែន បានបង្ហាញពីតួនាទីដ៏សំខាន់ក្នុងនាមជាក្រុមហ៊ុនបុត្រសម្ព័ន្ធផ្នែកហិរញ្ញវត្ថុរបស់ Hanshin Engineering And Contruction Co., ltd នៅកម្ពុជា។ យើងមានមោទនភាពនិងរំភើបយ៉ាងខ្លាំងចំពោះ ជោគជ័យ ហ្វាយនែន ដែលបានហែលឆ្លងកាត់ឧបសគ្គកន្លងមកដោយការណ៍នេះគឺបានឆ្លុះបញ្ចាំងតាមរយៈការកត់សំគាល់ដោយនិយ័តករក្នុងស្រុកជាពិសេសធនាគារជាតិនៃកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (ស៊ីអឹមអេ) ថាបានផ្តល់ផលប័ត្រកម្ចីខ្ពស់បំផុត ក្នុងចំណោមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រៀបធៀបទៅនឹងចំនួនសាខា។

ក្នុងនាមជាប្រធានក្រុមប្រឹក្សាភិបាល របស់គ្រឹះស្ថាន រយៈពេល ៣ឆ្នាំមកនេះខ្ញុំពិតជាមានការកោតសរសើរចំពោះភាពជាអ្នកដឹកនាំ និងការប្តេជ្ញាចិត្តរបស់គណៈគ្រប់គ្រងដែលពិតជាមានសមត្ថភាពក្នុងការដឹកនាំបុគ្គលិករបស់យើងដើម្បីនាំមកនូវជ័យជំនះ។ ក្រោមការត្រួតពិនិត្យនិងគំនិតច្នៃប្រឌិតថ្មីរបស់ពួកគាត់ ក្រុមការងារ និងបុគ្គលិកថ្នាក់ក្រោមបានយល់ច្បាស់អំពីអ្វីដែលអតិថិជនត្រូវការពិតប្រាកដ និងរចនាផលិតផលដែលសមស្របបំផុតដើម្បីបំពេញតម្រូវការទីផ្សារ។

ឆ្នាំ២០១៩ គឺជាឆ្នាំដែលជោគជ័យ បានពុះពារនូវបញ្ហាចំពោះមុខក៏ដូចជាសមិទ្ធិផលជាច្រើន។ វប្បធម៌ជោគជ័យត្រូវបានសម្រេចនឹងអនុវត្តធ្វើការជាមួយមនុស្សដែល ល្អបំផុតជាមួយនឹងការផ្លាស់ប្តូរមិនចេះចប់។ យើងបានដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវប្រព័ន្ធធនាគារស្នូលស្តង់ដារថ្មីជាសកលដើម្បីបង្កើនប្រតិបត្តិការនិងផលិតផលសេវាកម្មថ្មីរបស់យើង។ យើងបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងភាពជាដៃគូជាមួយ វីង និងទ្រូម៉ាន់នីថាជាភ្នាក់ងារផ្ទេរប្រាក់របស់យើង ដើម្បីផ្តល់ភាពងាយស្រួលដល់អតិថិជនក្នុងការទូទាត់សងប្រាក់កម្ចី។



ទិដ្ឋភាពទូទៅនៃសុខភាពហិរញ្ញវត្ថុសម្រាប់ស្ថាប័នធនាគារ និងមីក្រូហិរញ្ញវត្ថុបានបង្ហាញថា ស្ថេរភាពកំណើននៅតែបន្តមានចំពោះសាច់ប្រាក់ ងាយស្រួល ប្រាក់ចំណេញទ្រព្យសកម្ម និងមូលនិធិហិរញ្ញវត្ថុ។

# ទស្សនវិស័យ និង យុទ្ធសាស្ត្រសម្រាប់ឆ្នាំ ២០១៩

ទោះបីជាកំណើនសេដ្ឋកិច្ចនៅកម្ពុជា ត្រូវបានគេរំពឹងថានឹងថយចុះមកត្រឹម ២,៣% ក្នុងឆ្នាំ ២០២០ យើងនៅតែមើលឃើញឱកាសល្អៗសម្រាប់អាជីវកម្មមួយចំនួនដូចជា ស្បៀងអាហារ ភ័ស្តុភារ អាជីវកម្មតាមអនឡាញ និងសហគ្រាសធុនតូចនិង មធ្យម។ យើងនឹងធ្វើការបង្កើតសេវាកម្មដែលថ្មីល្អបំផុត ដើម្បីគាំទ្រដល់អតិថិជនរបស់យើងនិងគ្រួសារជាទីស្រឡាញ់របស់គេឲ្យមានស្ថេរភាពផ្នែកហិរញ្ញវត្ថុនិងរស់នៅប្រកបដោយផាសុកភាព។

ផ្តោតលើចក្ខុវិស័យវែងឆ្ងាយ ក្នុងការក្លាយទៅជាមីក្រូហិរញ្ញវត្ថុដែលមានកេរ្តិ៍ឈ្មោះ និងត្រូវបានគេទទួលស្គាល់ជាសកលនាពេលអនាគត យើងមានឆន្ទៈមោះមុត ក្នុងការប្រើប្រាស់បច្ចេកវិទ្យាទំនើបដើម្បីជាមធ្យោបាយក្នុងការពន្លឿនប្រតិបត្តិការរបស់ជោគជ័យ គ្រប់ផ្នែកឲ្យឈានមុខគេធៀបនឹងដៃគូរប្រកួតប្រជែង។ ជោគជ័យ នៅតែមានភាពជឿជាក់ចំពោះពាក្យថា "យកឈ្នះលើវិស័យធនាគារ" ព្រោះយើងមានការគាំទ្រយ៉ាងពេញទំហឹងពីម្ចាស់ភាគហ៊ុន Hanshin Engineering And Contruction Co., ltd និង Plus International Co., ltd ដែលជាក្រុមហ៊ុនអចលនទ្រព្យ ដែលបានចែករំលែក នឹងផ្តល់នូវយុទ្ធសាស្ត្រល្អៗ ដំណោះស្រាយជាក់ស្តែងផ្អែកលើបទពិសោធន៍ និង ថវិកាដើម្បីទ្រទ្រង់សុវត្ថិភាពកំណើនរបស់ជោគជ័យ។

ឆាប់ៗនេះយើងនឹងបើកការិយាល័យសាខាទី៧ និងទី៨ របស់យើងនៅខេត្តកំពង់ស្ពឺ និងកំពង់ឆ្នាំង ស្របគ្នានេះដែរយើងមានមោទនភាពជាខ្លាំងក្នុងការដំឡើងកម្មវិធីគ្រប់គ្រងធនធានមនុស្សក៏ដូចជាការប្រើប្រាស់ប្រព័ន្ធធនាគារស្នូលរបស់ខ្លួនឯងផ្ទាល់ឈ្មោះថា«អប្សរា»។ទាក់ទងនឹងផែនការអាជីវកម្ម៥ឆ្នាំរបស់យើង យើងក៏នឹងបោះជំហានទៅមុខដើម្បីក្លាយជាស្ថាប័នហិរញ្ញវត្ថុផ្អែកលើបច្ចេកវិទ្យា។

អ្វីដែលសំខាន់គួរឲ្យកត់សម្គាល់ផងដែរនោះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះសហការីដែលជាសមាជិកក្នុងជួរក្រុមប្រឹក្សាភិបាល លោកអគ្គនាយក ថ្នាក់ដឹកនាំជាន់ខ្ពស់ និង បុគ្គលិកគ្រប់ជាន់ថ្នាក់ទាំងអស់របស់ ជោគជ័យ ហ្វាយនែន ដែលបានចូល រួមចំណែកក្នុងការធ្វើឲ្យក្រុមហ៊ុនមានសន្ទុះទៅមុខប្រកបដោយនិរន្តរភាព។ ខ្ញុំក៏សូមឆ្លៀតយកឱកាសនេះថ្លែងអំណរគុណដល់អតិថិជន ភាគីពាក់ព័ន្ធអាជ្ញាធរ ដៃគូអាជីវកម្ម និង សហគមន៍ដែលបានផ្តល់នូវសុខសន្តិភាពការគាំទ្រ និងកិច្ចសហប្រតិបត្តិការជានិរន្ត ក្នុងការលើកកម្ពស់ទស្សនវិស័យនិងការប្តេជ្ញាចិត្តរបស់យើង ដើម្បីក្លាយជាស្ថាប័នហិរញ្ញវត្ថុលំដាប់ពិភពលោក។ គួរឱ្យកត់សម្គាល់ខ្ញុំសូមថ្លែងអំណរគុណចំពោះធនាគារជាតិនៃកម្ពុជាចំពោះការគាំទ្រជាបន្តបន្ទាប់។ ដើម្បីរក្សាសន្ទុះកំណើននៅឆ្នាំ២០២០ យើងសង្ឃឹមថានឹងបន្តទទួលបានការគាំទ្របន្តទៀតពីភាគីពាក់ព័ន្ធនីមួយៗ។

ដោយក្តីស្មោះត្រង់



**លោក MOON KYU CHOI**
ប្រធានក្រុមប្រឹក្សាភិបាល

# សាររបស់លោកអគ្គនាយក

សមិទ្ធិផលដ៏អស្ចារ្យ និង គួរឲ្យកត់សម្គាល់ដែលយើងមានចាប់តាំងពីការបង្កើត ជោគជ័យ ហ្វាយនែន ភីអិលស៊ី នៅពាក់កណ្ដាលឆ្នាំ២០១៦ ដោយម្ចាស់ភាគហ៊ុនក្នុងស្រុក ដែលក្រោយមកត្រូវបានធនាគារជាតិនៃកម្ពុជាផ្ដល់ការអនុញ្ញាតជាផ្លូវការ អំពីការផ្ទេរភាគហ៊ុនទៅម្ចាស់ភាគហ៊ុនកូរ៉េនៅខែសីហា ឆ្នាំ២០១៧ ។

គិតត្រឹម ខែធ្នូ ឆ្នាំ២០១៩ ជោគជ័យ មានធនធានមនុស្សប្រកបដោយសក្ដានុពលចំនួន ១៨៣នាក់ នៅការិយាល័យកណ្ដាលនិងសាខាប្រតិបត្តិការចំនួន ០៦ ដែលមានប្រាក់កម្ចីសរុបចំនួន ២១.៤លានដុល្លារ និង អតិថិជនចំនួន ១៨,៣៨៨ នាក់។ ក្នុងពេលដំណាលគ្នានេះដែរកំណើននៃវិស័យធនាគារ នៅកម្ពុជាសម្រាប់ឥណទាមានការកើនឡើងប្រហែល ២៥% ជាមធ្យមក្នុងរយៈពេល ៥ឆ្នាំចុងក្រោយនេះ ដែលជម្រុញឲ្យផលិតផលក្នុងស្រុកសរុបមានការកើនឡើងដល់ ១០៣% នៅក្នុងត្រីមាសទី២ នៃឆ្នាំ២០១៩ ។

ខ្ញុំពិតជាមានភាពរំភើបយ៉ាងក្រៃលែង ចំពោះភាពវៃឆ្លាតរបស់បុគ្គលិក ជោគជ័យ ជាពិសេសគណៈគ្រប់គ្រង និង បុគ្គលិក គ្រប់ជាន់ថ្នាក់ទាំងអស់ ដែលបានចូលរួមចំណែកឥតឈប់ឈរដើម្បីគាំទ្រដល់ភាពរីកចម្រើនរបស់ក្រុមហ៊ុន។កាលដែលយើងមានមកដល់ថ្ងៃនេះគឺដោយសារការចូលរួមពីអ្នកទាំងអស់គ្នា ការកំណត់គោលដៅដែលសមប្រកបផែនការយុទ្ធសាស្ត្រល្អៗ និង ធនធានដែលមានពោរពេញដោយសមត្ថភាពរបស់យើង។

អាថ៌កំបាំងចំពោះអាជីវកម្មជោគជ័យរបស់យើង បង្កប់នឹងវប្បធម៌ដែលយើងបង្កើតនៅកន្លែងធ្វើការ។ យើងស្វាគមន៍បុគ្គលគ្រប់រូបដែលមានទេពកោសល្យ ពីមជ្ឈដ្ឋានផ្សេងៗមកចូលរួមជាមួយយើង ជាមួយនឹងការប្រកាន់ភ្ជាប់នូវទស្សនវិស័យ "ធ្វើការជាមួយមនុស្សដែលល្អបំផុត"



"អព្យាក្រឹត្យភាព" "ការផ្លាស់ប្តូរអត់ឥតឈប់ឈរ" និង "ភាពស្មោះត្រង់គឺជាគោលយោបាយល្អបំផុត" ដើម្បីធានាបាននូវនិរន្តរភាពរបស់ក្រុមហ៊ុន។ អ្វីដែលធ្វើឲ្យយើងខុសពីអ្នកដទៃគឺ យើងផ្តល់សេវាកម្មលឿនបំផុត ក្នុងអត្រាការប្រាក់មួយទាប ដើម្បីធានានូវតម្រូវការទាន់ពេលវេលាសម្រាប់អតិថិជនរបស់យើង និងការយកចិត្តទុកដាក់ថែរក្សាប្រជាជនរបស់យើងដើម្បីឲ្យមានភាពរីកចម្រើនជាមួយគ្នា។

ប្រឈមមុខនឹងភាពមិនប្រាកដប្រជានៃពិភពលោកការផ្តោតលើបច្ចេក-វិទ្យានិង ភាពច្នៃប្រឌិតនៅតែជាអាទិភាពចម្បងរបស់យើង។យើងបានវិនិយោគធនធានរបស់យើងទាំងផ្នែក រូបវន្ត ហិរញ្ញវត្ថុ និងប្រព័ន្ធបច្ចេកវិទ្យាជាពិសេសទៅទៀតនោះគឺ ការអភិវឌ្ឍប្រព័ន្ធធនាគារស្នូល។ យើងចាប់ផ្តើមប្រើប្រាស់វេទិកាឌីជីថលដូចជា ប្រព័ន្ធផ្សព្វផ្សាយសង្គមដើម្បីជ្រើសរើសបុគ្គលិក និងស្វែងយល់បន្ថែមអំពីតម្រូវការរបស់អតិថិជន។

សមិទ្ធិផលការងារនាពេលអនាគត ឆ្លុះបញ្ចាំងពីសកម្មភាពបច្ចុប្បន្ន។ ខ្ញុំជឿជាក់លើប្រយោគដែលថា "គិតឲ្យបានមុន ចាត់វិធានការឲ្យហើយនិង ទទួលខុសត្រូវលើការងារ" គឺជាគន្លឹះដើម្បីជំរុញយើងឆ្ពោះទៅមុខ។ ឆ្នាំ២០២០ គឺជាឆ្នាំនៃបច្ចេកវិទ្យាទំនើប ដំណោះស្រាយប្រសើរជាងមុន និង សហគមន៍រីកចម្រើន។ យើងជាធនធានរបស់ ជោគជ័យ ប្តេជ្ញាបង្កើតនូវផលិតផលឌីជីថលថ្មី ចូលរួមចំណែកថែទាំដល់បរិស្ថានតាមរយៈយុទ្ធនាការផ្តួចផ្តើមផ្សេងៗ និង ជួយពង្រឹងប្រព័ន្ធសេដ្ឋកិច្ចកម្ពុជាឲ្យរឹងមាំ។ អ្វីដែលសំខាន់ផងដែរនោះ យើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អតិថិជនដែលតែងតែបន្តគាំទ្រ និង ដៃគូរអាជីវកម្មសម្រាប់ការសហការគ្នាប្រកបដោយទំនុកចិត្ត។

សូមអរគុណ!



**លោក CHEON GIL PARK**
អគ្គនាយក



# អំពីជោគជ័យ

## ប្រវត្តិរបស់ជោគជ័យ

### ២០១៦
អាជ្ញាបណ្ណប្រកបអាជីវកម្មជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុពី ធនាគារជាតិនៃកម្ពុជា(ខែមេសា)

### ២០១៧
ត្រូវបានទិញដោយក្រុមហ៊ុន កូរ៉េ ២គឺ **Hanshin E&C** និង **Plus International** (ខែសីហា)

### ២០១៨
- ខែមីនា ពង្រីក ៣សាខាថ្មី(ទួលគោក តាខ្មៅ និងថ្នល់ទទឹង)
- ខែកក្កដា ពង្រីក ២សាខាថ្មី(កំពង់ស្ពឺ និងជើងព្រៃ)

### ២០១៩
ផ្លាស់ប្តូរការប្រើប្រាស់ Core-banking ថ្មី "**Apsara**"(ខែឧសភា)

## តារាងសង្ខេបលទ្ធផលឆ្នាំ ២០១៩

### សមតុល្យផលប័ត្រឥណទានសរុប ( គិតជាដុល្លារ )




### ចំនួនអតិថិជនសរុប




### ចំនួនបុគ្គលិកសរុប




### ចំនួនបណ្តាញប្រតិបត្តិការ





CHOKCHEY
Finance

និមិត្តសញ្ញារបស់ ជោគជ័យ
ត្រូវបានគូសចេញពី " ទូកប្រណាំងខ្មែរ "

## ចក្ខុវិស័យ

យើងខិតខំប្រឹងប្រែងដើម្បីក្លាយជា ក្រុមហ៊ុនហិរញ្ញវត្ថុលំដាប់ពិភពលោក " វិសាលភាពលុបលើវិស័យធនាគារ" ទាំងលើទំហំផលចំណេញ និង "ការទទួលស្គាល់លើកិត្យានុភាព "(ភាពជឿជាក់ ភាពងាយស្រួល និងល្បឿននៃសេវាកម្ម) និង " ការបំពេញចិត្តដល់បុគ្គលិកគ្រប់ជាន់ថ្នាក់ "។

## បេសកកម្ម

ទទួលបាននូវភក្ដីភាពយូរអង្វែង ពីសំណាក់អតិថិជនគោលដៅស្ថិតក្នុងជីវភាពទាប និងមធ្យមតាមរយៈការផ្ដល់កម្ចី និងសេវាកម្មហិរញ្ញវត្ថុដើម្បីជួយលើកកម្ពស់ការរីកចម្រើននៃអាជីវកម្មប្រកបដោយនិរន្តរភាព ព្រមទាំងរួមចំណែកបង្កើតនូវ " វប្បធម៌នៃទម្លាប់ជោគជ័យ" សម្រាប់ជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគេ។

## វប្បធម៌

ជាស្ថាប័នប្រកបដោយសក្ដានុពល យើងមានចក្ខុ-វិស័យរួមជាសកលដើម្បីប្រែក្លាយជាក្រុមហ៊ុនលំដាប់ថ្នាក់ពិភពលោក ដោយឈរលើមូលដ្ឋានទម្លាប់នៃការបង្កើតភាពជោគជ័យនិងការអភិវឌ្ឍន៍សម្រាប់ការផ្លាស់ប្ដូរវិជ្ជមាន។ យើងទាំងអស់គ្នាប្រឹងប្រែងដើម្បីការរីកចម្រើនរួមគ្នា និងផ្ដល់ភាពរីករាយសម្រាប់ជីវិតឯកជនរបស់យើង។ យើងទាំងអស់គ្នាគឺគ្រួសារជោគជ័យ ហ្វាយនែន។

## ទស្សនៈវិស័យ

- ការផ្ដល់តម្លៃបុគ្គលិកជាធំ
- ភាពស្មោះត្រង់
- ចេះទទួលយកវប្បធម៌ការងារល្អ
- ការគោរពតួនាទីរៀងៗខ្លួន
- អព្យាក្រឹត្យភាព

# ភាគទុនិក




ក្រុមហ៊ុន Hanshin Engineering And Construction Co., Ltd




ក្រុមហ៊ុន Plus International Co., Ltd



## គម្រោងសំណង់ធំៗរបស់ក្រុមហ៊ុន HANSHIN E&C ក្នុងឆ្នាំ ២០១៩







# គម្រោងសាងសង់ផ្លូវជាតិលេខ ២ និងផ្លូវជាតិលេខ ៥ ក្នុងប្រទេសកម្ពុជា












# រចនាសម្ព័ន្ធគ្រឹះស្ថាន



# ក្រុមប្រឹក្សាភិបាល



## លោក MOON KYU CHOI
### ប្រធានក្រុមប្រឹក្សាភិបាល

- បច្ចុប្បន្នជាប្រធាននាយកប្រតិបត្តិក្រុមហ៊ុន Hanshin Engineering and Construction Co., Ltd
- បរិញ្ញាបត្រជាន់ខ្ពស់ពី Thunderbird School of Global Management, Arizona, USA
- បរិញ្ញាបត្រពី Sogang University, Seoul, Korea
- បុគ្គលិកក្រុមហ៊ុន Hyundai Merchant Marine
- បុគ្គលិកក្រុមហ៊ុន Hyundai Motor Company



## លោក JUNG HOON KIM
### អភិបាលឯករាជ្យ

- បច្ចុប្បន្នជាប្រធាននាយកដ្ឋានហិរញ្ញវត្ថុក្រុមហ៊ុន Success Promise Co., Ltd
- បរិញ្ញាបត្រផ្នែកពាណិជ្ជកម្មពី Sogang University, Seoul, Korea
- បុគ្គលិកក្រុមហ៊ុន Hyundai Marine & Fire Insurance



## លោក CHEON GIL PARK
### អភិបាល និងអគ្គនាយកប្រតិបត្តិ

- បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងពាណិជ្ជកម្មពី Yonsei University, Seoul, Korea
- វិញ្ញាបនប័ត្រផ្នែក Extension Marketing ពី UC Berkeley, California, USA
- បរិញ្ញាបត្រផ្នែកគ្រប់គ្រងពាណិជ្ជកម្មពី Sogang University, Seoul, Korea
- អគ្គនាយកគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ Green Central Microfinance
- ប្រធានគ្រប់គ្រងក្រុមហ៊ុន Samsung Card
- ប្រធានក្រុមការងារក្រុមហ៊ុន Hyundai Card
- ប្រធានផ្នែកទីផ្សារក្រុមហ៊ុន CJ Hellovision

# គណៈគ្រប់គ្រង



## លោក KEONGU KIM
### ប្រធាននាយក នាយកដ្ឋានហិរញ្ញវត្ថុ

- បទពិសោធន៍ជាង ១៣ឆ្នាំ ក្នុងផ្នែកគណនេយ្យ (ប្រទេសកូរ៉េខាងត្បូង អាស៊ីអាគ្នេយ៍ មជ្ឈឹមបូព៌ា)
- ធ្លាប់កាន់តំណែងជាប្រធានផ្នែកហិរញ្ញវត្ថុនៃក្រុមហ៊ុន Hanshin Engineering and Construction Co.,Ltd
- បរិញ្ញាបត្រផ្នែកគណនេយ្យនិងប្រព័ន្ធព័ត៌មាន



## លោក ចេង ប៊ុនធឿន
### ប្រធាននាយក នាយកដ្ឋានគ្រប់គ្រងហានិភ័យ

- បទពិសោធន៍ការងារជាង ៩ឆ្នាំ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ (អម្រឹត និង ហ្វ្រីនសេនត្រល)
- ចាប់ផ្តើមការងារពីមន្ត្រីឥណទាន មន្ត្រីគ្រប់គ្រងហានិភ័យ អនុប្រធានផ្នែកកម្ចី ប្រធានផ្នែកគ្រប់គ្រងហានិភ័យ និងនាយករងប្រតិបត្តិ
- បរិញ្ញាបត្រផ្នែកអភិវឌ្ឍសេដ្ឋកិច្ច (២០០៧)



## លោក សែន កំសាន្ត
### ប្រធាននាយក នាយកដ្ឋានឥណទាន

- បទពិសោធន៏ ១២ឆ្នាំនៅក្នុងវិស័យមីក្រូហិរញ្ញវត្ថុ (ប្រាសាក់ LOLC និង លីហ្សរ)
- បទពិសោធន៏ ៤ឆ្នាំនៅក្នុងវិស័យភ្នាក់ងារផេរលុយ
- ធ្លាប់កាន់តំណែងជាមន្ត្រីឥណទាន ប្រធានសាខារង ប្រធានសាខា ប្រធានប្រចាំតំបន់ ប្រធានផ្នែកគុណភាពសេវាកម្ម និង ប្រធានផ្នែកសេវាកម្មហិរញ្ញ-វត្ថុឌីជីថល



### លោក អ៊ុក តូរ៉ាគ្គីត
**នាយក នាយកដ្ឋានហិរញ្ញវត្ថុ**

- បទពិសោធន៍ការងារជាង៥ ឆ្នាំ នៅក្រុមហ៊ុនសវនកម្ម ខេភីអឹមជី (កម្ពុជា) ដែលទទួលបន្ទុកផ្ទាល់លើផ្នែកផ្សេងៗដូចជា គ្រឹះស្ថានហិរញ្ញវត្ថុ (ធនាគារ និងមីក្រូហិរញ្ញវត្ថុ) សាជីវកម្ម សណ្ឋាគារ អង្គការក្រៅរាជរដ្ឋាភិបាល និងគម្រោងរាជរដ្ឋាភិបាល ធ្លាប់ជាប្រធានហិរញ្ញវត្ថុនៅក្រុមហ៊ុន ភតិ សន្យា ប៊ីអេសភី ហ្វាយនែន ភីអិលស៊ី
- កំពុងបន្តការសិក្សាផ្នែកគណនេយ្យករជំនាញ ACCA នៅវិទ្យាស្ថាន CamEd Business School
- បរិញ្ញាបត្រផ្នែកគណនេយ្យឆ្នាំ ២០១២



### លោក លឹម រតនៈ
**នាយក នាយកដ្ឋានគ្រប់គ្រងហានិភ័យឥណទាន**

- បទពិសោធន៍ជាង ១១ឆ្នាំនៅក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ
- ធ្លាប់កាន់តំណែងជាមន្ត្រីឥណទានប្រតិបត្តិករ ប្រធានក្រុមឥណទាន នាយកសាខា និង ប្រធានផ្នែកហានិភ័យឥណទាន
- បរិញ្ញាបត្រផ្នែកអភិវឌ្ឍជនបទ (២០១១)



### លោក ណែម ម៉ានៀន
**នាយក នាយកដ្ឋានឥណទាន**

- បទពិសោធន៍ការងារជាង ៨ឆ្នាំនៅគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់
- ធ្លាប់កាន់តំណែងជាមន្ត្រីឥណទាន មន្ត្រីគ្រប់គ្រងឥណទានជាន់ខ្ពស់ នាយកសាខា ជំនួយការនាយកនាយកដ្ឋាន
- បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកធុរកិច្ចរដ្ឋបាល (២០១៥)



### លោក អ៊ឹម ផាន្នា
**នាយក នាយកដ្ឋានធនធានមនុស្ស**

- បទពិសោធន៍ការងារជាង៥ឆ្នាំ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ធនាគារ និង វិស័យអចលនទ្រព្យ
- ធ្លាប់កាន់តំណែងជាមន្ត្រីរដ្ឋបាល គ្រូបង្វឹកមន្ត្រីធនធានមនុស្ស មន្ត្រីធនធានមនុស្សជាន់ខ្ពស់ ប្រធានផ្នែកធនធានមនុស្ស
- ទទួលបានសញ្ញាប័ត្រផ្នែកគ្រប់គ្រងធនធានមនុស្ស និង ភាពជាអ្នកដឹកនាំ
- បរិញ្ញាបត្រ និង បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងទូទៅ



### លោក ដួង សត្យា
**នាយក នាយកដ្ឋានអាជីវកម្ម**

- បទពិសោធន៍ការងារជាង១១ឆ្នាំក្នុងវិស័យហិរញ្ញវត្ថុ
- ធ្លាប់កាន់តំណែងជា មន្ត្រីឥណទាន មន្ត្រីដោះស្រាយបំណុល នាយកសាខាជាន់ខ្ពស់ គ្រូបង្វឹក នាយករងប្រចាំសាខា ប្រធានផ្នែកឥណទាន និងដោះស្រាយបំណុល ប្រធានប្រចាំតំបន់
- បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកធុរកិច្ចពាណិជ្ជកម្ម (២០១៣)



### លោក ហំ សំណាង
**នាយក នាយកដ្ឋានព័ត៌មានវិទ្យា**

- បទពិសោធន៍ការងារជាង ៥ឆ្នាំ ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ និង ៦ឆ្នាំនៅក្នុងវិស័យឯកជន
- ធ្លាប់កាន់តំណែងជាអ្នកសរសេរកម្មវិធីព័ត៌មានវិទ្យា អ្នកអភិវឌ្ឍន៍កម្មវិធីជាន់ខ្ពស់ ប្រធានផ្នែកគាំទ្រអតិថិជន ប្រធានផ្នែកប្រព័ន្ធគ្រប់គ្រងព័ត៌មាន អនុប្រធានផ្នែកព័ត៌មានវិទ្យា
- បរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រកុំព្យូទ័រ



## លោកស្រី ច័ន្ទ ដានី
### នាយក នាយកដ្ឋានរតនាភិបាល

- បទពិសោធន៍ជាង១២ ឆ្នាំក្នុងវិស័យមីក្រូហិរញ្ញវត្ថុ
- បម្រើការនៅអង្គការក្រៅរដ្ឋាភិបាលទទួលបន្ទុកគម្រោងអភិវឌ្ឍសង្គម សុខភាពកុមារ និងស្ត្រី និងអភិវឌ្ឍធនធានមនុស្ស
- ធ្លាប់កាន់តំណែងជាបេឡាធិការ ប្រធានបេឡា មន្ត្រីផ្នែកសេវាអតិថិជន មន្ត្រីផ្នែកលក់និងមន្ត្រីជាន់ខ្ពស់រតនាភិបាល



## លោក ហាន ច័ន្ទជំនោ
### នាយក នាយកដ្ឋាន នីតិកម្មនិងប្រតិបត្តិតាម

- ធ្លាប់ជាអ្នកបកប្រែជាន់ខ្ពស់ បកប្រែផ្ទាល់មាត់ និងជាប្រធានផ្នែកត្រួតពិនិត្យគុណភាព និងជានាយកសាខាគ្រឹះស្ថានអប់រំ
- បរិញ្ញាបត្រផ្នែកសេដ្ឋកិច្ចឆ្នាំ ២០១១ និងបរិញ្ញាបត្រផ្នែកអប់រំឆ្នាំ ២០១២



## លោក ម៉ុន រស្មី
### នាយក នាយកដ្ឋាន គ្រប់គ្រងកិច្ចការរដ្ឋបាលទូទៅ

- បទពិសោធន៍ការងារជាង ៨ ឆ្នាំក្នុងវិស័យមីក្រូហិរញ្ញវត្ថុ
- ធ្លាប់កាន់តំណែងជាមន្ត្រីឥណទាន មន្ត្រីរដ្ឋបាល មន្ត្រីរដ្ឋបាលជាន់ខ្ពស់ ប្រធានផ្នែករដ្ឋបាល
- បរិញ្ញាបត្រជាន់ខ្ពស់ផ្នែករដ្ឋបាលធុរកិច្ច (២០១៩)



## លោកស្រី ពេជ្រ សូរិយា
### នាយករង នាយកដ្ឋានហិរញ្ញវត្ថុ

- បទពិសោធន៍ការងារជាង ៩ ឆ្នាំក្នុងវិស័យមីក្រូហិរញ្ញវត្ថុ និងធនាគារឯកទេស
- ធ្លាប់កាន់តំណែងជាមន្ត្រីឥណទាន មន្ត្រីឥណទានជាន់ខ្ពស់ នាយកតំបន់ ប្រធានផ្នែកឥណទាន និងនាយករងសាខា
- បរិញ្ញាបត្រផ្នែកហិរញ្ញវត្ថុ និងធនាគារ (២០១៤)



## លោក អ៊ុន សេងទ្រឿ
### នាយករង នាយកដ្ឋានសវនកម្មផ្ទៃក្នុង

- បទពិសោធន៍ការងារជាង ៩ ឆ្នាំក្នុងវិស័យមីក្រូហិរញ្ញវត្ថុ (ជោគជ័យ និង អម្រឹត)
- ធ្លាប់កាន់តំណែងជាមន្ត្រីឥណទាន មន្ត្រីឥណទានជាន់ខ្ពស់ មន្ត្រីសវនកម្មផ្ទៃក្នុង មន្ត្រីសវនកម្មផ្ទៃក្នុងជាន់ខ្ពស់ ប្រធានគ្រប់គ្រងផ្នែកសវនកម្មផ្ទៃក្នុង
- បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកហិរញ្ញវត្ថុ និងធនាគារ (២០១៦)



## លោក ឈូ សុខលាភ
### នាយករង នាយកដ្ឋាន ដោះស្រាយបំណុល

- បទពិសោធន៍ការងារជាង ១១ឆ្នាំក្នុងវិស័យមីក្រូហិរញ្ញវត្ថុ (ហ្វ្រីដ៏នហ្វាយនែន វើលខាំហ្វាយនែន និង ជោគជ័យហ្វាយនែន)
- ធ្លាប់កាន់តំណែងជាមន្ត្រីបម្រើសេវាអតិថិជន មន្ត្រីឥណទាន ប្រធានមន្ត្រីឥណទាន ប្រធានសាខា និង ប្រធានផ្នែកសវនកម្មផ្ទៃក្នុង
- បរិញ្ញាបត្រ និង បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកហិរញ្ញវត្ថុ និងធនាគារ



### លោក ញិល ធារុទ្ធ
នាយករង នាយកដ្ឋាន ព័ត៌មានវិទ្យា

- បទពិសោធន៏ការងារជាង ៧ឆ្នាំ ក្នុងការអភិវឌ្ឍន៏ប្រព័ន្ធធនាគារស្នូល ប្រព័ន្ធគ្រប់គ្រងមន្ទីរពេទ្យ និងប្រព័ន្ធគ្រប់គ្រងផ្នែកធនធានមនុស្ស
- បរិញ្ញាបត្រផ្នែកគ្រប់គ្រងប្រព័ន្ធព័ត៌មាន (២០១៣)



### កញ្ញា តារា រតនៈរស្មី
នាយិការង នាយកដ្ឋាន ធនធានមនុស្ស និង ទីផ្សារ

- បទពិសោធន៏ការងារជាង៤ឆ្នាំ ក្នុងវិស័យហិរញ្ញវត្ថុ មជ្ឈមណ្ឌលបណ្តុះបណ្តាល និងពាណិជ្ជកម្មអេឡិចត្រូនិច
- បរិញ្ញាបត្រផ្នែកធុរកិច្ចពាណិជ្ជកម្ម (២០១៥) និង បរិញ្ញាបត្រផ្នែកអក្សរសាស្រ្តភាសាអង់គ្លេស (២០១៧)
- បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកធុរកិច្ចពាណិជ្ជកម្មសកល (២០១៩) សាកលវិទ្យាល័យសភាពាណិជ្ជកម្មថៃ ទីក្រុងបាងកក



### លោក ALEXANDER JAMES EVISON
នាយករង នាយកដ្ឋាន អាជីវកម្មឌីជីថល

- បទពិសោធន៏ការងារជាង៤ឆ្នាំ ក្នុងវិស័យហិរញ្ញវត្ថុ
- ជំនាញការងារនៅផ្នែកបដិសណ្ឋារកិច្ច ធានារ៉ាប់រង និង FinTech
- ធ្លាប់បានសិក្សានៅគ្រឹះស្ថានអប់រំជាច្រើន នៅប្រទេសអង់គ្លេស និង ហូឡង់
- សិក្សាផ្នែកប្រព័ន្ធព័ត៌មាន នៅ Heriot-Watt University, Edinburgh

## ប្រភពទុនវិនិយោគ

PPCBank, KB Kookmin Bank, Industrial Bank of Korea

## ដៃគូរសហការ

true money, Wing, mobile C&C

## យើងមានមោទនភាពជាខ្លាំងក្នុងការក្លាយជាសមាជិកនៃ

EUROCHAM CAMBODIA



# សមិទ្ធិផលអាជីវកម្ម ឆ្នាំ២០១៩



## ផលិតផលកម្ចី

### កម្ចីទូទៅ




ប្រភេទកម្ចីដើម្បីគាំទ្រដល់លំហូរសាច់ប្រាក់នៃការចំណាយក្នុងគ្រួសារ ឬ ការវិនិយោគប្រភេទណាមួយ។ វាអាចត្រូវបានប្រើប្រាស់សម្រាប់ការទិញដី ជួសជុលឬទិញផ្ទះ បើកដំណើរការឬពង្រីកអាជីវកម្ម និងការចំណាយចាំបាច់សម្រាប់គ្រួសារជាទីស្រឡាញ់របស់ពួកគេ។

| | |
|---|---|
| **ទំហំកម្ចី** | ធំជាង ៣.០០០ រហូតដល់ ៣០.០០០ ដុល្លារអាមេរិក ឬ រូបិយប័ណ្ណសមមូល |
| **រយៈពេលកម្ចី** | រហូតដល់ ៧២ខែ |
| **របៀបបង់សង** | សងរំលស់ប្រាក់ដើម និងការប្រាក់ប្រចាំខែសងការប្រាក់ និងប្រាក់ដើមថេរប្រចាំខែសងការប្រាក់និងប្រាក់ដើមតាមដំណាក់កាលសងរំលស់ប្រាក់ដើមតាមការចរចារសងការប្រាក់រៀងរាល់ខែ និងប្រាក់ដើម នៅចុងវគ្គ |
| **រូបិយប័ណ្ណ** | ប្រាក់រៀល ដុល្លារអាមេរិក |

# កម្ចីកសិកម្ម






គោលបំណងនៃការប្រើប្រាស់គឺដើម្បីផ្តល់ដើមទុនដល់អតិថិជនក្នុងការវិនិយោគលើគ្រាប់ពូជរុក្ខជាតិ ឧបករណ៍កសិកម្មធុន់ៗ ឬ ទិញដី សម្រាប់សកម្មភាពដាំដុះកសិកម្ម។

| | |
|---|---|
| **ទំហំកម្ចី** | • រហូតដល់ ៥.០០០ដុល្លារ ឬរូបិយប័ណ្ណសមមូល ចំពោះគោលបំណងកម្ចីក្នុងការបង្កបង្កើនផលកសិកម្ម<br>• រហូតដល់ ១៥.០០០ដុល្លារ ឬរូបិយប័ណ្ណសមមូល ចំពោះគោលបំណងកម្ចីទិញឧបករណ៍កសិកម្មធំៗ និងទិញដីកសិកម្មបង្កបង្កើនផលកសិកម្ម។ |
| **រយៈពេលកម្ចី** | រហូតដល់ ៧២ខែ |
| **របៀបបង់សង** | បង់ប្រាក់ដើមនៅចុងវគ្គ និងការប្រាក់ប្រចាំខែ បង់ប្រាក់ដើមរំលស់ថេរ និង ការប្រាក់ប្រចាំខែ បង់ប្រាក់ដើម និងការប្រាក់ រំលស់ថេរប្រចាំ |
| **រូបិយប័ណ្ណ** | ប្រាក់រៀល ដុល្លារអាមេរិក |





# កម្ចីទាន់ចិត្ត






កញ្ចប់នៃប្រភេទកម្ចីពិសេសមួយ សម្រាប់តម្រូវការបន្ទាន់ក្នុងការប្រើប្រាស់ទូទៅសម្រាប់ខ្លួនឯងផ្ទាល់ ឬ ក្រុមគ្រួសារ។ សេវាកម្មនេះនឹងផ្តល់លំហូរសាច់ប្រាក់ងាយស្រួល និង រហ័សទាន់ចិត្តដល់ដៃអតិថិជន។

| | |
|---|---|
| **ទំហំកម្ចី** | រហូតដល់ ៣.០០០ ដុល្លារអាមេរិក ឬរូបិយប័ណ្ណសមមូល |
| **រយៈពេលកម្ចី** | រហូតដល់ ៣៦ខែ |
| **របៀបបង់សង** | បង់ប្រាក់ដើមរំលស់ថេរ និងការប្រាក់ប្រចាំខែ បង់ប្រាក់ដើម និងការប្រាក់រំលស់ថេរប្រចាំខែ |
| **រូបិយប័ណ្ណ** | ប្រាក់រៀល ដុល្លារអាមេរិក |

## កម្ចីអេសអឹមអ៊ី







ឥណទាននេះត្រូវបានបង្កើតឡើងសម្រាប់អតិថិជនដែលកំពុងស្វែងរកការចាប់ផ្តើមអាជីវកម្មផ្ទាល់ខ្លួនរួមមានផលិតផល សេវាកម្ម សិប្បកម្ម សំណង់ និង ផលិតផលជាច្រើនទៀត។

| | |
|---|---|
| **ទំហំកម្ចី** | ធំជាង ៣០.០០០ ដល់ ១០០.០០០ ដុល្លារអាមេរិក |
| **រយៈពេលកម្ចី** | ចាប់ពី ១២ខែ ដល់ ១២០ខែ ទៅតាមលទ្ធភាពសង និងគោលបំណងខ្ចីប្រាក់របស់អតិថិជន |
| **របៀបបង់សង** | បង់ប្រាក់ដើមនៅចុងវគ្គ និងការប្រាក់ប្រចាំខែ បង់ប្រាក់ដើមរំលស់ថេរ និងការប្រាក់ប្រចាំខែ បង់ប្រាក់ដើម |
| **រូបិយប័ណ្ណ** | ប្រាក់ដុល្លារអាមេរិក |

## កម្ចីយានយន្ត






ដើម្បីនាំមកនូវការរស់នៅប្រកបដោយផាសុកភាព សម្រាប់ប្រជាពលរដ្ឋខ្មែរផលិតផលនេះត្រូវបានរចនាឡើងសម្រាប់ជាជំនួយថវិកាក្នុងការទិញយានជំនិះដែលសមនឹងជីវភាពរបស់ពួកគេជាមួយនឹងប្រាក់តម្កល់អប្បបរមា ១០ភាគរយ។

| | |
|---|---|
| **ទំហំកម្ចី** | ១.៥០០ រហូតដល់ ៥០.០០០ ដុល្លារ |
| **រយៈពេលកម្ចី** | រហូតដល់ ៦០ខែ |
| **របៀបបង់សង** | បង់ប្រាក់ដើម និងការប្រាក់រំលស់ថេរប្រចាំខែ |
| **រូបិយប័ណ្ណ** | ប្រាក់ដុល្លារអាមេរិក |

# ការិយាល័យសាខារបស់ជោគជ័យ







- **ភ្នំពេញ**

### ១. ការិយាល័យកណ្ដាល និងសាខាស្ទឹងមានជ័យ

ផ្ទះលេខ ៩-១១ ផ្លូវវេងស្រេង សង្កាត់ស្ទឹងមានជ័យ ៣
ខណ្ឌមានជ័យ រាជធានីភ្នំពេញ
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៩២២ ១២៦ / ០១៥ ២០៤ ៣៣៣
គេហទំព័រ: www.chokchey.com.kh

### ២. សាខាទួលគោក

ផ្លូវឧកញ៉ា ម៉ុង ឫទ្ធី ភូមិគង្គាផុស សង្កាត់ទួលសង្កែទី២
ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៩២២ ១២៦ / ០១៥ ៣៦៧ ៣៣៣

- **ខេត្តកណ្ដាល**

### ៣. សាខាតាខ្មៅ

ផ្លូវលេខ ១១៥ ភូមិព្រែកសំរោង៣ សង្កាត់តាខ្មៅ
ក្រុងតាខ្មៅ ខេត្តកណ្ដាល
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៩២២ ១២៦ / ០១៥ ៤១៨ ៣៣៣

- **ខេត្តកំពង់ស្ពឺ**

### ៤. សាខាថ្នល់ទទឹង

ផ្លូវជាតិលេខ ៤ ភូមិព្រៃគុយ ឃុំត្រពាំងគង
ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៩២២ ១២៦ / ០១៥ ៤៦២ ៣៣៣

### ៥. សាខាកំពង់ស្ពឺ

ភូមិអង្គសេរី សង្កាត់រកាធំ ក្រុងច្បារមន ខេត្តកំពង់ស្ពឺ
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៩២២ ១២៦ / ០១៥ ៤៩៦ ៣៣៣

- **ខេត្តកំពង់ចាម**

### ៦. សាខាជើងព្រៃ

ភូមិស្គន់ ឃុំសូទិព្វ ស្រុកជើងព្រៃ ខេត្តកំពង់ចាម
ទូរស័ព្ទលេខ: (៨៥៥) ២៣ ៩២២ ១២៦ / ០១៥ ៣២៩ ៣៣៣

# ព្រឹត្តិការណ៍សខ្ទេបឆ្នាំ២០១៩

## Singapore FinTech Festival (វិច្ឆិកា)




## ដំណើរទស្សនកិច្ចថ្នាក់ដឹកនាំនៅទីក្រុងសេអ៊ូល (ឧសភា)






## វគ្គបណ្ដុះបណ្ដាលសម្រាប់អនាគតថ្នាក់ដឹកនាំ





## ដំណើរទស្សនកិច្ចនៃនាយកដ្ឋានឥណទាន







## សិក្ខាសាលាប្រចាំឆ្នាំ (Annual Workshop)





## កម្មវិធីពិពណ៌ការងារថ្នាក់ជាតិ





## កម្មវិធីជប់លៀងបុគ្គលិកប្រចាំឆ្នាំ





## កម្មវិធីជប់លៀងទិវាវប្បធម៌ស្ត្រី






# ភាពជោគជ័យរបស់អតិថិជន



**សេង ណាត អាយុ ៣៤ ឆ្នាំ**
ឱសថការី និងជាគ្រូពេទ្យពិគ្រោះជម្ងឺទូទៅ

*" និយាយទៅតាំងពីខ្ញុំបានស្គាល់ជោគជ័យមក អាជីវកម្មរបស់ខ្ញុំចេះតែរីកចម្រើន និងទទួលបានជោគជ័យដូចពាក្យ ជោគជ័យ អញ្ចឹងដែរ" មានប្រសាសន៍ដោយលោក សេងណាត ។*

ទីលំនៅចំងាយប្រមាណ ៤៣ គីឡូម៉ែត្រពីទីក្រុងភ្នំពេញ លោកណាត រស់នៅក្នុងតំបន់ដែលមានចរាចរណ៍អាជីវកម្មខ្ពស់ នៅទីតាំងផ្ទះលេខ ១១២បេ ផ្លូវជាតិលេខ ៣ ភូមិត្រាំខ្នារ ឃុំសូភី ស្រុកបាទី ខេត្តតាកែវ។ គាត់មានគ្រួសារដ៏កក់ក្ដៅមួយដែលមានកូនពីរនាក់ ប្រពន្ធរបស់គាត់ជាគិលានុបដ្ឋាយិការស់នៅស្រុកជាមួយគ្នា។

មុនពេលខ្ចីប្រាក់ពី ជោគជ័យ លោកណាត និងភរិយាបានបើកគ្លីនិកនិងប្រកបអាជីវកម្មជាមួយគ្នា។ ប៉ុន្តែដោយមើលឃើញពីសក្ដានុពលនៃតម្រូវការរបស់កម្មកររោងចក្រនិងអ្នកភូមិ គាត់ក៏មានគំនិតចង់បើកសាខាគ្លីនិកបន្ថែមប៉ុន្តែគាត់ខ្វះដើមទុន។ មិនយូរប៉ុន្មានមន្ត្រីឥណទានម្នាក់មកពីក្រុមហ៊ុន ជោគជ័យ ហ្វាយនែន បានចុះជួបនិងផ្ដល់ការប្រឹក្សាយោបល់ផ្នែកហិរញ្ញវត្ថុដល់គាត់ដែលទីបំផុតគាត់បានស្នើសុំដាក់ពាក្យសុំប្រាក់ កម្ចីអេសអឹមអ៊ី ចំនួន ១២០.០០០ ដុល្លារ។

ដោយប្រកាន់ខ្ជាប់នូវផែនការរបស់គាត់ លោកណាតសម្រេចចិត្តបើកគ្លីនិកជាមួយនឹងកម្ចីដែលលោកទទួលបានពី ជោគជ័យ និង ទុកខ្លះដើម្បីវិនិយោគទៅលើដីធ្លី។ បច្ចុប្បន្ននេះទោះបីអាជីវកម្មមួយចំនួនត្រូវ បានរងការប៉ះពាល់ក៏ដោយក៏គាត់នៅតែរកប្រាក់ចំណូលបានស្ថេរភាព ពីគ្លីនិកទាំងពីរហើយថែមទាំងអាចសន្សំប្រាក់ សម្រាប់តម្រូវការកូនៗរបស់គាត់នាពេលអនាគត។

ជាចុងក្រោយលោកបានលើកឡើងថាអរគុណដល់ ជោគជ័យ ដែលបានជួយជំរុញផែនការអាជីវកម្មរបស់លោក ឱ្យទៅជាការពិត។ នាពេលអនាគត គាត់ចង់បើកគណនីសន្សំសម្រាប់កូនៗរបស់គាត់ជាមួយជោគជ័យ ប្រសិនបើជោគជ័យព្រមទទួលប្រាក់បញ្ញើ។





**ប្អូន ចាន់ធឿន អាយុ ៣៩ឆ្នាំ**
អាជីវករលក់គ្រឿងបន្លាស់ម៉ូតូ

*"ខ្ញុំចាំថានៅថ្ងៃខ្លះ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ២-៣ ព្យាយាមមកបញ្ចុះបញ្ចូលខ្ញុំឱ្យប្រើប្រាស់សេវាកម្មរបស់ពួកគេ ប៉ុន្តែខ្ញុំនៅតែជ្រើសរើសក្រុមហ៊ុនជោគជ័យពីព្រោះសេវាកម្មលឿនហើយ ពួកគាត់ធ្វើតាមការសន្យារបស់ពួកគេ" មានប្រសាសន៍ដោយលោក ចាន់ធឿន ។*

លោកចាន់ធឿនជាឪពុក និងប្តីឧស្សាហ៍ម្នាក់ដែលបានបង្កើតគ្រួសារដ៏មានសុភមង្គលនិងមានសមាជិកចំនួន ៥នាក់ រស់នៅផ្ទះលេខ ៥០ ផ្លូវលេខ ០១ ភូមិព្រៃជើងព្រំ ឃុំវាលស្បូវ សង្កាត់ច្បារអំពៅ រាជធានីភ្នំពេញ។

មុនពេលចាប់ផ្តើមអាជីវកម្មផ្ទាល់ខ្លួន គាត់ធ្លាប់ជាអ្នកលក់នៅក្រុមហ៊ុនគ្រឿងបន្លាស់ធំមួយ។ ជាមួយនឹងការប្តេជ្ញាចិត្តរបស់គាត់ដើម្បីក្លាយជាអ្នកជំនួញឯករាជ្យម្នាក់ គាត់បានសម្រេចចិត្តឈប់ធ្វើការ ហើយចាប់ផ្តើមបើកហាងរបស់គាត់ជាមួយប្រាក់ដែលគាត់សន្សំតិចតួចអំឡុងពេលធ្វើការ។ ពីមួយថ្ងៃទៅមួយថ្ងៃ អតិថិជន ដែលចូលមកទិញតែងតែមានតម្រូវការ និង ជម្រើសម៉ាកផ្សេងៗគ្នាដែលគាត់មិនមាន។ ដូច្នេះហើយទើបលោកសម្រេចចិត្តស្នើសុំប្រាក់កម្ចីពីជោគជ័យចំនួន ៤៥.០០០ ដុល្លារ ដើម្បីទិញ អីវ៉ាន់ និង ម៉ាកផលិតផល ជាច្រើនប្រភេទស្តុកទុកសម្រាប់បំពេញតម្រូវការរបស់អតិថិជន។

បច្ចុប្បន្នអាជីវកម្មគ្រឿងបន្លាស់របស់លោក បាននាំមកនូវលំហូរសាច់ប្រាក់គ្រប់គ្រាន់ សម្រាប់ក្រុមគ្រួសាររបស់លោក និងថែមទាំងផ្តល់នូវឱកាសវិនិយោគបន្ថែមទៀត លើមុខជំនួញហាងសាឡនរបស់ភរិយាលោក ដែលកំពុងបើកដំណើរនៅក្នុងអគារតែមួយ។

នៅចុងបញ្ចប់លោកចាន់ធឿនបានមានប្រសាសន៍ថា តាមរយៈការសង្កេតរបស់គាត់ គាត់សម្លឹងឃើញឱកាសដ៏ល្អសម្រាប់ពង្រីកអាជីវកម្មថ្មីរបស់គាត់ជាមួយ នឹងគ្រឿងបន្លាស់រថយន្ត ព្រោះថានៅក្នុងតំបន់ដែលគាត់រស់នៅ មិនទាន់មានអ្នកណាចាប់ផ្តើមអាជីពនេះនៅឡើយទេ។ ដូច្នេះលោកកំពុងទន្ទឹងរងចាំកិច្ចសហប្រតិបត្តិការបន្ថែមទៀតជាមួយ ជោគជ័យ នៅពេលសេដ្ឋកិច្ច មានស្ថេរភាពមកវិញ។



# របាយការណ៍ហិរញ្ញវត្ថុ



# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល សូមដាក់ជូននូវរបាយការណ៍នេះភ្ជាប់ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជោគជ័យ ហ្វាយនែន ភីអិលស៊ី ("ក្រុមហ៊ុន") នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ និង សម្រាប់ចុងការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩។

## ក្រុមហ៊ុន

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជោគជ័យ ហ្វាយនែន ភីអិលស៊ី ("ក្រុមហ៊ុន") ក្រុមហ៊ុនសាធារណៈទទួលខុសត្រូវមានកម្រិត ដែលបានបង្កើតនៅព្រះរាជាណាចក្រកម្ពុជា និងបានចុះបញ្ជី នៅក្រសួងពាណិជ្ជកម្ម ក្រោមវិញ្ញាបនបត្រចុះបញ្ជីលេខ ០០០០២៩៥២ ចុះនៅថ្ងៃទី២ ខែមីនា ឆ្នាំ២០១៦។ ក្រុមហ៊ុនបានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា ដើម្បីដំណើរការជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦។

ទីស្នាក់ការចុះបញ្ជីរបស់ក្រុមហ៊ុនមានទីតាំងស្ថិតនៅ ផ្ទះលេខ ៩-១១ ផ្លូវ វេងស្រេង សង្កាត់ស្ទឹងមានជ័យទី៣ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។

## សកម្មភាពអាជីវកម្មចម្បង

សកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុន គឺផ្តល់ឲ្យសាធារណជាមួយ និងសេវាហិរញ្ញវត្ថុប្រកបដោយនិរន្តរភាពអោយមីក្រូសហគ្រិនខ្នាតតូច និងមធ្យម និងគ្រួសារដែលមានប្រាក់ចំណូលទាបនៅក្នុងប្រទេសកម្ពុជា។

## លទ្ធផលនៃប្រតិបត្តិការ

លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនប្រចាំឆ្នាំ និងស្ថានភាពនៃប្រតិបត្តិការរបស់ក្រុមហ៊ុននាកាលបរិច្ឆេទនោះ ត្រូវបានកំណត់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុចាប់ពីទំព័រទី១១ដល់ទំព័រទី ៤៥។

ក្រុមប្រឹក្សាភិបាលពុំមានការស្នើ ការបែងចែក ឬការប្រកាសភាគលាភ នាចុងការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩។

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទ និងនាកាលបរិច្ឆេទនៃរបាយការណ៍នេះ មានដូចតទៅ៖

| ឈ្មោះ | មុខតំណែង | កាលបរិច្ឆេទតែងតាំង |
|---|---|---|
| លោក Moon Kyu Choi | ប្រធានក្រុមប្រឹក្សាភិបាល | ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៧ |
| លោក Cheon Gil Park | អភិបាល | ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៧ |
| លោក Jung Hoon Kim | អភិបាលឯករាជ្យ | ថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៧ |

## សវនករ

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៩ ត្រូវបានធ្វើសវនកម្ម ដោយក្រុមហ៊ុន ប្រ៊ែគ្គន សនថុន (ខេមបូឌា) លីមីតធីត។

## ភាគកម្មរបស់ក្រុមប្រឹក្សាភិបាល

អនុលោមទៅតាមលក្ខន្តិកៈ របស់ញាតិសម្ព័ន្ធរបស់ក្រុមហ៊ុន ក្រុមប្រឹក្សាភិបាលពុំមានភាគកម្មក្នុងភាគហ៊ុនរបស់ក្រុមហ៊ុនក្នុង ការិយបរិច្ឆេទហិរញ្ញវត្ថុនេះទេ។

## ព្រឹត្តិការណ៍ក្រោយរបាយការណ៍

មិនមានព្រឹត្តិការណ៍សំខាន់ៗ គួរអោយកត់សម្គាល់ក្នុងកំឡុង ពេលបរិច្ឆេទរបាយការណ៍រហូតដល់ ពេលបរិច្ឆេទនៃការអនុម័ត នៃរបាយការណ៍ហិរញ្ញវត្ថុ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវ ក្នុងការរៀបចំរបាយការណ៍ ហិរញ្ញវត្ថុទាំងនេះ ដើម្បីបង្ហាញទិដ្ឋភាពពិតនិងត្រឹមត្រូវ សម្រាប់ ស្ថានភាពហិរញ្ញវត្ថុនាកាលបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ព្រមទាំងលទ្ធផលនៃប្រតិបត្តិការអាជីវកម្ម និងស្ថានភាពលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទនេះ។ក្នុងការរៀបចំរបាយការណ៍ ហិរញ្ញវត្ថុទាំងនេះ ក្រុមប្រឹក្សាភិបាលតម្រូវឲ្យ៖

(ក) ជ្រើសរើសគោលនយោបាយគណនេយ្យ ឲ្យបានសមស្រប ដោយផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ស្មានសមហេតុផល និងប្រុងប្រយ័ត្ន ហើយបន្ទាប់មកធ្វើការអនុវត្តគោលនយោបាយទាំងនេះឲ្យមានសង្គតិភាព

(ខ) អនុលោមតាមស្តង់ដាររបាយការណ៍ ទាក់ទងនឹងហិរញ្ញវត្ថុ អន្តរជាតិនៃកម្ពុជាសម្រាប់អង្គភាពខ្នាតតូច និងមធ្យមហើយ ប្រសិនបើមានការប្រាសចាកណាមួយ ពីស្តង់ដារទាំងនេះ ក្នុងការបង្ហាញនូវទិដ្ឋភាពពិតនិងត្រឹមត្រូវក្រុមប្រឹក្សាភិបាល ត្រូវប្រាកដថាការប្រាសចាកទាំងនេះ ត្រូវបានលាតត្រដាង ពន្យល់ និងកំណត់បរិមាណឲ្យបានត្រឹមត្រូវនៅក្នុងរបាយ ការណ៍ហិរញ្ញវត្ថុ

(គ) ធានាឲ្យបាននូវភាពគ្រប់គ្រាន់នៃការកត់ត្រាគណនេយ្យ និង ប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឲ្យមានប្រសិទ្ធិភាព

(ឃ) រៀបចំរបាយការណ៍ហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននិរន្តភាព នៃដំណើរការអាជីវកម្ម លុះត្រាតែមានករណីមិនសមរម្យ ក្នុងការសន្មតថាក្រុមហ៊ុន នឹងបន្តធ្វើប្រតិបត្តិការអាជីវកម្ម នាពេលអនាគតដែលអាចរំពឹងទុកបាន

(ង) ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុន ឲ្យមានប្រសិទ្ធភាពលើរាល់ សេចក្តីសម្រេចចិត្តសំខាន់ៗ ដែលប៉ះពាល់ដល់ប្រតិបត្តិការ និងដំណើរការរបស់ក្រុមហ៊ុន ហើយត្រូវប្រាកដថាកិច្ចការនេះត្រូវបានឆ្លុះបញ្ចាំង យ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាល ក៏មានទំនួលខុសត្រូវក្នុងការថែរក្សាទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ហើយក៏ត្រូវចាត់វិធានការឲ្យសមស្រប ដើម្បីទប់ស្កាត់ និងរកឲ្យឃើញការក្លែងបន្លំ និងភាពមិនប្រក្រតីផ្សេងៗ។

ក្រុមប្រឹក្សាភិបាលធានាអះអាងថាក្រុមហ៊ុនបានអនុវត្តតាមរាល់ តម្រូវការខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

## សេចក្តីថ្លែងការណ៍របស់ក្រុមប្រឹក្សាភិបាល

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល របាយការណ៍ហិរញ្ញវត្ថុ ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ របាយការណ៍ ចំណេញ ឬខាត និងចំណូលពេញលេញ របាយការណ៍បម្រែបម្រួលមូលធន របាយកាណ៍លំហូរសាច់ប្រាក់ព្រមទាំងកំណត់ សម្គាល់របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងយ៉ាងសមរម្យ និងបង្ហាញទិដ្ឋភាពពិត និងត្រឹមត្រូវទៅតាមស្ថានភាពហិរញ្ញវត្ថុ របស់ក្រុមហ៊ុននាការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ព្រមទាំងលទ្ធផលប្រតិបត្តិការ និងលំហូរសាច់ប្រាក់របស់ក្រុមហ៊ុន សម្រាប់ចុងការិយបរិច្ឆេទ ដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ អន្តរជាតិនៃកម្ពុជាសម្រាប់អង្គភាព ខ្នាតតូច និងមធ្យម។

ជំនួសឲ្យក្រុមប្រឹក្សាភិបាល




**លោក Cheon Gil Park**
អគ្គនាយកប្រតិបត្តិ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ២០២០

# របាយការណ៍របស់សវនករឯករាជ្យ

**ជូនចំពោះភាគហ៊ុននិករបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជោគជ័យ ហ្វាយនែន ភីអិលស៊ី**

## មតិយោបល់

យើងបានធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុ របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជោគជ័យ ហ្វាយនែន ភីអិលស៊ី ("ក្រុមហ៊ុន") ដែលរួមមាន របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នាការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ របាយការណ៍ចំណេញ ឬខាត និងចំណូលពេញលេញ របាយការណ៍បម្រែបម្រួលមូលធន របាយកាណ៍លំហូរសាច់ប្រាក់នាចុងការិយបរិច្ឆេទ កំណត់សំគាល់របាយការណ៍ហិរញ្ញវត្ថុ និងសេចក្តីសង្ខេបកំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុផ្សេងៗ រួមទាំងគោលនយោបាយគណនេយ្យសង្ខេបសំខាន់ៗ និងព័ត៌មានពន្យល់ផ្សេងទៀត។

តាមមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុបានបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុ របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ជោគជ័យ ហ្វាយនែន ភីអិលស៊ី នាការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ព្រមទាំងលទ្ធផលនៃប្រតិបត្តិការអាជីវកម្មនិងស្ថានភាពលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទនេះដោយអនុលោម ទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់អង្គភាព ខ្នាតតូចនិងមធ្យម។

## មូលដ្ឋាននៃការបញ្ចេញមតិយោបល់

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាម ស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា។ ការទទួលខុសត្រូវរបស់យើងខ្ញុំស្ថិតក្រោមស្តង់ដារទាំងនោះ ត្រូវបានរៀបរាប់បន្ថែមទៀតនៅក្នុងផ្នែកការទទួលខុសត្រូវរបស់សវនករទៅលើ ការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ។ យើងមានឯករាជ្យភាព ក្នុងការធ្វើសវនកម្មដោយ អនុលោមតាមស្តង់ដារនៃវិជ្ជាជីវៈគណនេយ្យអន្តរជាតិ "ក្រមសីលធម៌ របស់គណនេយ្យករជំនាញ" រួមជាមួយនិងតម្រូវការក្រមសីលធម៌ ដែលពាក់ព័ន្ធទៅនឹងការធ្វើសវនកម្មរបស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា ហើយយើងបានបំពេញការទទួលខុសត្រូវទៅតាមតម្រូវការ និង ក្រមសីលធម៌ទាំងនោះ។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មទាំងឡាយដែលយើងទទួលបានគឺគ្រប់គ្រាន់ និងសមរម្យដើម្បីផ្តល់ជូនជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិរបស់យើង។

## កំណត់សម្គាល់ផ្សេងទៀត

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ត្រូវបានធ្វើសវនកម្ម ដោយសវនករផ្សេងទៀត ដែលបានបញ្ចេញមតិយោបល់នៅថ្ងៃទី ២២ ខែមេសា ឆ្នាំ ២០១៩ ថារបាយការណ៍ហិរញ្ញវត្ថុ របស់ក្រុមហ៊ុនបានបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវ។

## ព័ត៌មានផ្សេងទៀត

គណៈគ្រប់គ្រង មានទទួលខុសត្រូវចំពោះព័ត៌មានផ្សេងទៀត។ ព័ត៌មានផ្សេងទៀតរួមមានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល ប៉ុន្តែមិនរាប់បញ្ចូលរបាយការណ៍ របស់សវនករនិងរបាយការណ៍ហិរញ្ញវត្ថុដែលយើងទទួលបានមុនកាលបរិច្ឆេទ នៃរបាយការណ៍របស់សវនករនេះ រួមទាំងរបាយការណ៍ប្រចាំឆ្នាំដែលរំពឹងថានឹងផ្តល់ជូនពួកយើងបន្ទាប់ពីកាលបរិច្ឆេទនោះ។

មតិយោបល់របស់យើងលើរបាយការណ៍ហិរញ្ញវត្ថុមិនគ្របដណ្តប់លើព័ត៌មានផ្សេងទៀតទេ ហើយយើងមិនបង្ហាញពីទម្រង់ណាមួយនៃការធានាសវនកម្ម ឬការសន្និដ្ឋានណាមួយទៅលើព័ត៌មានទាំងនោះឡើយ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ទំនួលខុសត្រូវរបស់ពួកយើងគឺអានព័ត៌មានផ្សេងទៀត ដូចដែលបានរៀបរាប់ខាងលើ ដើម្បីពិចារណាថាតើព័ត៌មានទាំងនោះអាចនឹងមានភាពមិនស៊ីសង្វាក់គ្នាជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុ ឬចំណេះដឹងរបស់យើងដែលទទួលបានពីការធ្វើសវនកម្មកន្លងមក ឬអាចបង្ហាញពីកំហុសឆ្គងជាសារវន្ត។

ប្រសិនបើផ្អែកលើការអានព័ត៌មានផ្សេងទៀត ដែលយើងទទួលបានមុនកាលបរិច្ឆេទនៃរបាយការណ៍សវនករនេះ ហើយយើងសន្និដ្ឋានថា មានភាពមិនត្រឹមត្រូវគួរឱ្យកត់សម្គាល់ណាមួយ យើងនឹងធ្វើការរាយការណ៍ អំពីភាពមិនប្រក្រតីទាំងនោះតាមភាពជាក់ស្តែង។បន្ទាប់ពីបានអានព័ត៌មានផ្សេងទៀតដែលផ្តល់ជូនដោយគណៈគ្រប់គ្រងនៃក្រុមហ៊ុន យើងមិនមានអ្វីត្រូវរាយការណ៍អំពីភាពមិនប្រក្រតីនោះទេ។

ក្នុងករណីប្រសិនបើយើងសន្និដ្ឋានថា មានភាពមិនប្រក្រតីណាមួយ យើងតម្រូវឱ្យរាយការណ៍អំពីបញ្ហានេះទៅក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុន ព្រមទាំងឆ្លើយតបនឹងបញ្ហានោះដោយអនុលោមតាមតម្រូវការស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជាលេខ ៧២០ (កែសំរួលថ្មី) ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវក្នុងការរៀបចំ និងការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ឲ្យបានត្រឹមត្រូវដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់អង្គភាពខ្នាតតូច និងមធ្យម និងទទួលខុសត្រូវលើការត្រួតពិនិត្យផ្ទៃក្នុង ដែលក្រុមប្រឹក្សាភិបាលកំណត់ថាវាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ មិនឲ្យមានការរាយការណ៍ខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬ កំហុសឆ្គងផ្សេងៗ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ក្រុមប្រឹក្សាភិបាលមានទំនួលខុសត្រូវចំពោះការវាយតម្លៃសមត្ថភាព ក្រុមហ៊ុនក្នុងការបន្តប្រតិបត្តិការដោយផ្អែកលើមូលដ្ឋាននិរន្តភាព ការលាតត្រដាងប្រសិនជាមានបញ្ហាទាក់ទងនឹងនិរន្តភាព និងការប្រើប្រាស់និរន្តភាពជាមូលដ្ឋានគណនេយ្យ លុះត្រាតែក្រុមប្រឹក្សាភិបាលមានគោលបំណងរំសាយក្រុមហ៊ុន ឬបញ្ឈប់ប្រតិបត្តិការ ឬក៏គ្មានជម្រើសផ្សេងប៉ុន្តែចាំបាច់ត្រូវធ្វើ។

## ការទទួលខុសត្រូវរបស់សវនករទៅលើការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំគឺដើម្បីទទួលបាននូវការធានាអះអាងដ៏សមហេតុផល ទៅលើរបាយការណ៍ហិរញ្ញវត្ថុ ដោយពុំមានលក្ខណៈខុសឆ្គងជាសារវន្ត បណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គង ហើយនិងការបញ្ចេញមតិយោបល់លើរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ ការធានាអះអាងដែលសមហេតុផលគឺជាការធានាមួយដ៏ខ្ពស់ ប៉ុន្តែវាមិនបានធានាថា ការធ្វើសវនកម្មដោយផ្អែកទៅលើស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា នឹងតែងតែរកឃើញនូវការរាយការណ៍ខុសជាសារវន្តដែលមានឡើយ។ ការរាយការណ៍ខុសអាចកើតមានឡើងពីការក្លែងបន្លំ ឬកំហុសឆ្គងដែលអាចចាត់ទុកថាជាសារវន្ត នៅពេលដែលកំហុសមួយ ឬកំហុសរួមគ្នា បានធ្វើឲ្យប៉ះពាល់ដល់សេចក្តីសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃការធ្វើសវនកម្ម ដោយយោងទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជាយើងអនុវត្តនូវវិជ្ជាជីវៈវិនិច្ឆ័យនិងការសន្និដ្ឋានដែលមានវិជ្ជាជីវៈទៅលើការធ្វើសវនកម្ម។ពួកយើងក៏៖

- កំណត់អត្តសញ្ញាណ និងវាយតម្លៃនូវហានិភ័យពីការរាយការណ៍ខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ ថាតើវាកើតឡើងដោយការក្លែងបន្លំ ឬកំហុសឆ្គងដោយអចេតនា រៀបចំ និងអនុវត្តនិតិវិធីសវនកម្ម ដែលឆ្លើយតបទៅនឹងហានិភ័យទាំងនោះ រួមទាំងការប្រមូលយកភស្តុតាងសវនកម្មឲ្យបានគ្រប់គ្រាន់ និងសមស្រប ដើម្បីគាំទ្រជាមូលដ្ឋានសម្រាប់បញ្ចេញមតិយោបល់របស់យើង។ ហានិភ័យដែលមិនអាចរកឃើញដោយការរាយការណ៍ខុស ជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ គឺធំជាងកំហុសឆ្គងដោយអចេតនា ដោយសារតែការក្លែងបន្លំរួមបញ្ចូលទាំងការរួមគំនិត ការក្លែងបន្លំដោយចេតនា ការលុបចោលដោយចេតនា ការបង្ហាញខុស ឬ ការលើសលប់ទៅលើការត្រួតពិនិត្យផ្ទៃក្នុង។
- ធ្វើការស្វែងយល់អំពីការគ្រប់គ្រងផ្ទៃក្នុង ដែលទាក់ទងទៅនឹងការធ្វើសវនកម្ម ដើម្បីបង្កើតនូវនិតិវិធីសវនកម្មដែលសមស្របទៅនឹងកាលៈទេសៈ ប៉ុន្តែមិនមែនជាគោលបំណងក្នុងការបង្ហាញនូវមតិយោបល់ លើប្រសិទ្ធិភាពគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុននោះឡើយ ។
- ធ្វើការវាយតម្លៃភាពសមស្របលើ គោលនយោបាយគណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃគណនេយ្យប៉ាន់ស្មាន ក៏ដូចជាការបង្ហាញនានាដែលធ្វើឡើងដោយក្រុមប្រឹក្សាភិបាល សន្និដ្ឋានដ៏សមស្របមួយទៅលើការប្រើប្រាស់របស់គណៈគ្រប់គ្រង លើមូលដ្ឋាននិរន្តភាពគណនេយ្យ ផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន ថាតើភាពមិនប្រាកដប្រជាជាសារវន្តបានកើតឡើងទាក់ទិននឹងព្រឹត្តិការណ៍ ឬ លក្ខខណ្ឌដែលធ្វើឲ្យមានមន្ទិលសង្ស័យខ្លាំងទៅលើលទ្ធភាពការបន្តនិរន្តភាពរបស់ក្រុមហ៊ុន។
- ប្រសិនបើយើងសន្និដ្ឋានថា ភាពមិនប្រាកដប្រជាជាសារវន្តនឹងកើតមានឡើង យើងតម្រូវឲ្យធ្វើការលាតត្រដាងព័ត៌មានចាំបាច់ដើម្បីទាញការយកចិត្តទុកដាក់ នៅក្នុងរបាយការណ៍សវនកម្មរបស់យើង ទៅនឹងការលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬក៏ប្រសិនបើការលាតត្រដាងនោះមិនគ្រប់គ្រាន់ នោះមតិយោបល់មិនត្រឹមត្រូវ ត្រូវបានបញ្ចេញ។ ការសន្និដ្ឋានរបស់យើងខ្ញុំគឺផ្អែកទៅលើ ភស្តុតាងសវនកម្មដែលទទួលបាន គិតត្រឹមថ្ងៃនៃការចេញរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ក៏ប៉ុន្តែស្ថានភាពឬក៏ព្រឹត្តិការណ៍នាពេលអនាគតអាចបណ្តាលឲ្យ និងក្រុមហ៊ុនមិនអាចបន្តប្រតិបត្តិការជានិរន្តភាពបាន។
- វាយតម្លៃការបង្ហាញទូទៅទម្រង់ និងអត្ថន័យរបស់របាយការណ៍ហិរញ្ញវត្ថុ រួមបញ្ចូលទាំងការលាតត្រដាងនានាថាតើរបាយការណ៍ហិរញ្ញវត្ថុបង្ហាញនូវប្រតិបត្តិការ និងព្រឹត្តិ-ការណ៍នានា ដើម្បីបង្ហាញនូវភាពត្រឹមត្រូវ សមស្របរបស់វា។

យើងប្រាស្រ័យទាក់ទងជាមួយនឹងក្រុមប្រឹក្សាភិបាលទៅលើបញ្ហាផ្សេងៗ ការរៀបចំដែនកំណត់ និងពេលវេលាក្នុងការធ្វើសវនកម្ម និងរបបគំហើញសវនកម្មសំខាន់ៗ រួមបញ្ចូលទាំងកង្វះខាតធំៗមួយចំនួនទៅលើការគ្រប់គ្រងផ្ទៃក្នុងដែលពួកយើងខ្ញុំរកឃើញកំឡុងពេលធ្វើសវនកម្ម។

យើងខ្ញុំក៏ផ្តល់ជូនក្រុមប្រឹក្សាភិបាល នូវសេចក្តីថ្លែងការណ៍មួយដែលយើងខ្ញុំបានអនុវត្តទៅតាមតម្រូវការក្រមសីលធម៌ដែលទាក់ទងនឹងឯករាជ្យភាព ហើយយើងខ្ញុំធ្វើការរាយការណ៍ជូនក្រុមប្រឹក្សាភិបាលនូវបញ្ហាទាំងអស់ ដែលនឹងគិតថាសមហេតុផលទៅលើឯករាជ្យភាពរបស់យើងខ្ញុំ និងការការពារដែលអាចមាន។



**ហ្គ្រេន សនថុន ខេមបូឌា លីមីតធីត**

គណនេយ្យករជំនាញ

សវនករប្រតិស្រុតចុះបញ្ជី





**Ronald C. Almera**

នាយកសវនករជំនាញ

ក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី ១៤ ខែ សីហា ឆ្នាំ២០២០





# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

| | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣.២) ត្រូវបានកែប្រែឡើងវិញ |
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៥ | ៥៥,២៣៨ | ២២៥,០៩៥ | ៤៥,៤០២ | ១៨២,៤២៥ |
| ប្រាក់បញ្ញើនិងប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា | ៦ | ១៧៧,១៧១ | ៧២១,៩៧២ | ២,០៧៥,៥០០ | ៨,៣៣៩,៣៥៩ |
| ប្រាក់បញ្ញើ និងតម្កល់នៅធនាគារនានា | ៧ | ២,០៣៧,៣៩៨ | ៨,៣០២,៣៩៧ | ៦៨៨,៨៣៦ | ២,៧៦៧,៧៤៣ |
| ឥណទានទៅអោយអតិថិជន | ៨ | ២១,៥៣៧,៤៩១ | ៨៧,៧៦៥,២៧៦ | ១៣,២៦៤,០៨៣ | ៥៣,២៩៥,០៨៥ |
| ទ្រព្យសកម្មផ្សេងៗ | ៩ | ៦១,៩៣១ | ២៥២,៣៦៩ | ២៧,៦២២ | ១១០,៩៨៥ |
| ទ្រព្យ និង បរិក្ខារ | ១០ | ៣៦០,៦៩០ | ១,៤៦៩,៨១២ | ១៨០,៥៥៧ | ៧២៥,៤៧៨ |
| ទ្រព្យអរូបី | ១១ | ១០២,៥៧៨ | ៤១៨,០០៥ | ២៧,០០២ | ១០៨,៤៩៤ |
| **ទ្រព្យសកម្មសរុប** | | **២៤,៣៣២,៤៩៧** | **៩៩,១៥៤,៩២៦** | **១៦,៣០៩,០០២** | **៦៥,៥២៩,៥៦៩** |

| | | | | | |
|---|---|---|---|---|---|
| **មូលធន** | | | | | |
| ភាគហ៊ុនដើមទុន | ១២ | ៣,៥០០,០០០ | ១៤,០៦៣,០០០ | ១,៥០០,០០០ | ៦,០២៧,០០០ |
| ទុនបម្រុង | | - | - | ២,០០០,០០០ | ៨,០៣៦,០០០ |
| ទុនបម្រុងតាមបទបញ្ញត្តិ | | ៣៨៨,៥៧៤ | ១,៥៧៣,៤៤៦ | ១៥០,៨៤១ | ៦១០,១៥២ |
| ខាតបង្គរ | | (២២២,៧៧៩) | (៨៩៦,១៥៥) | (៦១៤,៦២០) | (២,៤៨៣,៨៩៥) |
| លម្អៀងនៃការប្តូររូបិយប័ណ្ណ | | - | ១៩៧,៨២៥ | - | ១០,២៧៨ |
| **មូលធនសរុប** | | **៣,៦៦៥,៧៩៥** | **១៤,៩៣៨,១១៦** | **៣,០៣៦,២២១** | **១២,១៩៩,៥៣៥** |
| | | | | | |
| **បំណុល** | | | | | |
| ការជួញដូរ និងគណនីត្រូវទូទាត់ផ្សេងៗ | ១៣ | ៣៨៧,៤៥៩ | ១,៥៧៨,៨៩៥ | ២៧២,៧៨១ | ១,០៩៦,០៣៤ |
| កម្ចីរយៈពេលខ្លី | ១៤ | ៦,៧៤៧,៥៤៦ | ២៧,៤៩៦,២៥០ | - | - |
| កម្ចីរយៈពេលវែង | ២០ | ១៣,៥០០,០០០ | ៥៥,០១២,៥០០ | ១៣,០០០,០០០ | ៥២,២៣៤,០០០ |
| ពន្ធលើប្រាក់ចំណូលត្រូវបង់ | | ៣១,៦៩៧ | ១២៩,១៦៥ | - | - |
| **បំណុលសរុប** | | **២០,៦៦៦,៧០២** | **៨៤,២១៦,៨១០** | **១៣,២៧២,៧៨១** | **៥៣,៣៣០,០៣៤** |
| **បំណុល និងមូលធនសរុប** | | **២៤,៣៣២,៤៩៧** | **៩៩,១៥៤,៩២៦** | **១៦,៣០៩,០០២** | **៦៥,៥២៩,៥៦៩** |



# របាយការណ៍ចំណេញ ឬខាតនិងចំណូលពេញលេញផ្សេងៗ

| | | សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | | សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣.២) ត្រូវបានកែប្រែឡើងវិញ |
| ចំណូលការប្រាក់ | ១៥ | ៣,០៤៧,៤៧៩ | ១២,៣៤៨,៣៨៤ | ១,៤៦៣,១០៣ | ៥,៩១៨,២៥២ |
| ចំណាយការប្រាក់ | | (៩៤៤,១៥២) | (៣,៨២៥,៧០៤) | (៤៣៨,៩៩៩) | (១,៧៧៥,៧៥១) |
| **ចំណូលការប្រាក់សុទ្ធ** | | **២,១០៣,៣២៧** | **៨,៥២២,៦៨០** | **១,០២៤,១០៤** | **៤,១៤២,៥០១** |
| ប្រាក់ចំណូលផ្សេងៗ | ១៦ | ៤៤៨,៣៧៧ | ១,៨១៦,៨២៤ | ១៣៧,៨៨៧ | ៥៥៧,៧៥៣ |
| ចំណាយទូទៅ និងរដ្ឋបាល | ១៧ | (១,៨៧៨,២៧២) | (៧,៦១០,៧៥៨) | (១,២៩៤,២៩៥) | (៥,២៤៥,២៨៥) |
| សំវិធានធនសម្រាប់ឥណទានបាត់បង់ និងជាប់សង្ស័យ | | ២៣,៤៣៨ | ៩៤,៩៧១ | (២១,៦៩៥) | (៧៧,៨៩៥) |
| **ប្រាក់ចំណូលឬខាតមុនពន្ធ** | | **៦៩៦,៨៧០** | **២,៨២៣,៧១៧** | **(១៥៣,៩៩៩)** | **(៦២២,៩២៦)** |
| ចំណាយពន្ធលើប្រាក់ចំណូល | ១៨ | (៦៧,២៩៦) | (២៧២,៦៨៣) | (១៥,៤៣១) | (៦២,៤១៨) |
| **ប្រាក់ចំណូលឬខាតសុទ្ធចុងគ្រា** | | ៦២៩,៥៧៤ | ២,៥៥១,០៣៤ | (១៦៩,៤៣០) | (៦៨៥,៣៤៤) |
| ចំណូលពេញលេញផ្សេងៗ៖ លម្អៀងពីអត្រាប្តូររូបិយប័ណ្ណ | | - | ១៨៧,៥៤៧ | - | ១០,២៧៨ |
| **ចំណូលឬខាតពេញលេញសរុប សម្រាប់ការិយបរិច្ឆេទ** | | **៦២៩,៥៧៤** | **២,៧៣៨,៥៨១** | **(១៦៩,៤៣០)** | **(៦៧៥,០៦៦)** |

# របាយការណ៍បម្រែបម្រួលមូលធន

| | | ដើមទុន | | ទុនបម្រុង | | ខាតបង្គរ | | ទុនបម្រុងតាមបទបញ្ញត្តិ | | លម្អៀងនៃការប្តូររូបិយប័ណ្ណ | ដើមទុនសរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣.២) | ពាន់រៀល (កំណត់សម្គាល់ ៣.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣.២) |
| ថ្ងៃទី១ ខែមករា ឆ្នាំ២០១៩ | | ១,៥០០,០០០ | ៦,០២៧,០០០ | ២,០០០,០០០ | ៨,០៣៦,០០០ | (៦១៤,៦២០) | (២,៤៨៣,៨៩៥) | ១៥០,៨៤១ | ៦១០,១៥២ | ១០,២៧៨ | ៣,០៣៦,២២១ | ១២,១៩៩,៥៣៥ |
| ផ្ទេរពីទុនបម្រុងទៅ ភាគហ៊ុនដើមទុន | ១២ | ២,០០០,០០០ | ៨,០៣៦,០០០ | (២,០០០,០០០) | (៨,០៣៦,០០០) | - | - | - | - | - | - | - |
| ចំនេញក្នុងគ្រា | | - | - | - | - | ៦២៩,៥៧៤ | ២,៥៥១,០៣៤ | - | - | - | ៦២៩,៥៧៤ | ២,៥៥១,០៣៤ |
| ផ្ទេរពីខាតបង្គរទៅទុនបម្រុងតាមបទបញ្ញត្តិ | | - | - | - | - | (២៣៧,៧៣៣) | (៩៦៣,២៩៤) | ២៣៧,៧៣៣ | ៩៦៣,២៩៤ | - | - | - |
| លម្អៀងនៃការប្តូររូបិយប័ណ្ណ | | - | - | - | - | - | - | - | - | ១៨៧,៥៤៧ | - | ១៨៧,៥៤៧ |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩** | | **៣,៥០០,០០០** | **១៤,០៦៣,០០០** | - | - | **(២២២,៧៧៩)** | **(៨៩៦,១៥៥)** | **៣៨៨,៥៧៤** | **១,៥៧៣,៤៤៦** | **១៩៧,៨២៥** | **៣,៦៦៥,៧៩៥** | **១៤,៩៣៨,១១៦** |

| | | ដើមទុន | | ទុនបម្រុង | | ខាតបង្គរ | | ទុនបម្រុងតាមបទបញ្ញត្តិ | | លម្អៀងនៃការប្តូររូបិយប័ណ្ណ | ដើមទុនសរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣.២) | ពាន់រៀល (កំណត់សម្គាល់ ៣.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣.២) |
| ថ្ងៃទី១ ខែមករា ឆ្នាំ២០១៨ | | ១,៥០០,០០០ | ៦,០២៧,០០០ | - | - | (២៧៩,៧០៦) | (១,១២៩,១៧៣) | - | - | - | ១,២២០,២៩៤ | ៤,៨៩៧,៨២៧ |
| និយ័តកម្មលើកដំបូងនៃCIFRS for SMEs (សម្គាល់ ២៣) | | - | - | - | - | (៤៣,៨៤៨) | (១៧៧,៣៦០) | ២៩,២០៥ | ១១៨,១៣៤ | - | (១៤,៦៤៣) | (៥៩,២២៦) |
| សមតុល្យនាថ្ងៃទី១ ខែមករា ឆ្នាំ២០១៨ បន្ទាប់ពីធ្វើនិយ័តកម្ម | | ១,៥០០,០០០ | ៦,០២៧,០០០ | - | - | (៣២៣,៥៥៤) | (១,៣០៦,៥៣៣) | ២៩,២០៥ | ១១៨,១៣៤ | - | ១,២០៥,៦៥១ | ៤,៨៣៨,៦០១ |
| ទុនចូលរួមបន្ថែមក្នុងគ្រា | ១២ | - | - | ២,០០០,០០០ | ៨,០៣៦,០០០ | - | - | - | - | - | ២,០០០,០០០ | ៨,០៣៦,០០០ |
| ខាតក្នុងគ្រា | | - | - | - | - | (១៦៩,៤៣០) | (៦៨៥,៣៤៤) | - | - | - | (១៦៩,៤៣០) | (៦៨៥,៣៤៤) |
| ផ្ទេរពីខាតបង្គរទៅទុនបម្រុងតាមបទបញ្ញត្តិ | | - | - | - | - | (១២១,៦៣៦) | (៤៩២,០១៨) | ១២១,៦៣៦ | ៤៩២,០១៨ | - | - | - |
| លម្អៀងនៃការប្តូររូបិយប័ណ្ណ | | - | - | - | - | - | - | - | - | ១០,២៧៨ | - | ១០,២៧៨ |
| **សមតុល្យនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨** | | **១,៥០០,០០០** | **៦,០២៧,០០០** | **២,០០០,០០០** | **៨,០៣៦,០០០** | **(៦១៤,៦២០)** | **(២,៤៨៣,៨៩៥)** | **១៥០,៨៤១** | **៦១០,១៥២** | **១០,២៧៨** | **៣,០៣៦,២២១** | **១២,១៩៩,៥៣៥** |

# របាយការណ៍លំហូរសាច់ប្រាក់

| | | សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ | | សម្រាប់ចុងការិយបរិច្ឆេទ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ | |
|---|---|---|---|---|---|
| | កំណត់សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣.២) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ៣.២) ត្រូវបានកែប្រែឡើងវិញ |
| **សកម្មភាពប្រតិបត្តិការ** | | | | | |
| ប្រាក់ចំណូលឬខាតមុនបង់ពន្ធ | | ៦៩៦,៨៧០ | ២,៨២៣,៧១៧ | (១៥៣,៩៩៩) | (៦២២,៩២៦) |
| **និយ័តកម្មសម្រាប់៖** | | | | | |
| រំលស់ទ្រព្យរូបី | ១០ | ៧២,៥៤១ | ២៩៣,៩៣៦ | ៤២,០៨៥ | ១៧០,២៣៤ |
| រំលស់ទ្រព្យអរូបី | ១១ | ៣,៤៥៩ | ១៤,០១៦ | ២,៨៩៩ | ១១,៧២៦ |
| សំវិធានធនសម្រាប់ឥណទានបាត់បង់ និងជាប់សង្ស័យ | | (២៣,៤៣៨) | (៩៤,៩៦៧) | ២១,៦៩៥ | ៨៧,៧៥៦ |
| **ប្រតិបត្តិការចំណូលឬខាតមុនបម្រែបម្រួល ដើមទុន** | | **៧៤៩,៤៣២** | **៣,០៣៦,៧០២** | **(៨៧,៣២០)** | **(៣៥៣,២១០)** |
| **បម្រែបម្រួលនេះ** | | | | | |
| ប្រាក់តម្កល់ធានាលើដើមទុននៅធនាគារជាតិនៃកម្ពុជា | | (១០០,០០០) | (៤០៥,២០០) | (២៥,០០០) | (១០១,១២៥) |
| ប្រាក់បញ្ញើមានកំណត់ | | (១,៤០០,០០០) | (៥,៦៧២,៨០០) | - | - |
| ឥណទានទៅអតិថិជន | | (៨,២៤៣,៧៦២) | (៣៣,៤០៣,៧២៧) | (១០,៨១៧,៨១៨) | (៤៣,៧៥៨,០៧៣) |
| ទ្រព្យផ្សេងៗ | | (៤០,៥១៧) | (១៦៤,១៧៥) | ៨,២១៧ | ៣៣,២៣៨ |
| បំណុលផ្សេងៗ | | ១១៤,៦៧៨ | ៤៦៤,៦៧៥ | ២៣៩,៤៩៨ | ៩៦៨,៧៦៩ |
| **សាច់ប្រាក់សុទ្ធប្រើក្នុងប្រតិបត្តិការ** | | **(៨,៩២០,១៦៩)** | **(៣៦,១៤៤,៥២៥)** | **(១០,៦៨២,៤២៣)** | **(៤៣,២១០,៤០១)** |
| ពន្ធលើប្រាក់ចំណេញដែលបានបង់ | | (៣៥,៥៩៩) | (១៤៤,២៤៧) | (១៥,៤៣១) | (៦២,៤១៨) |
| **សាច់ប្រាក់សុទ្ធប្រើនៅក្នុងប្រតិបត្តិការ** | | **(៨,៩៥៥,៧៦៨)** | **(៣៦,២៨៨,៧៧២)** | **(១០,៦៩៧,៨៥៤)** | **(៤៣,២៧២,៨១៩)** |
| **សកម្មភាពវិនិយោគ** | | | | | |
| ការទិញទ្រព្យសកម្ម | | (២៥២,៦៧៤) | (១,០២៣,៨៣៥) | (៨៦,៦៩៣) | (៣៥០,៦៧៣) |
| ការទិញទ្រព្យអរូបី | | (៧៩,០៣៥) | (៣២០,២៥០) | (១០,៣៥០) | (៤១,៨៦៦) |
| **សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពវិនិយោគ** | | **(៣៣១,៧០៩)** | **(១,៣៤៤,០៨៥)** | **(៩៧,០៤៣)** | **(៣៩២,៥៣៩)** |
| **សកម្មភាពហិរញ្ញប្បទាន** | | | | | |
| កម្ចីក្នុងគ្រា | | ៨,២៤៧,៥៤៦ | ៣៣,៤១៩,០៥៦ | ១០,៦១១,៥៥៧ | ៤២,៩២៣,៧៤៨ |
| ការទូទាត់សងប្រាក់កម្ចី | | (១,០០០,០០០) | (៤,០៥២,០០០) | - | - |
| ការដាក់ទុនបន្ថែមក្នុងគ្រា | | - | - | ២,០០០,០០០ | ៨,០៩០,០០០ |
| **សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មហិរញ្ញប្បទាន** | | **៧,២៤៧,៥៤៦** | **២៩,៣៦៧,០៥៦** | **១២,៦១១,៥៥៧** | **៥១,០១៣,៧៤៨** |
| **បម្រែលបម្រួលសាច់ប្រាក់សុទ្ធក្នុងដៃ និងសាច់ប្រាក់សមមូល** | | **(២,០៣៩,៩៣១)** | **(៨,២៦៥,៨០១)** | **១,៨១៦,៦៦០** | **៧,៣៤៨,៣៩០** |
| លម្អៀងនៃការប្តូររូបិយប័ណ្ណ | | - | ១០៨,៩៦៣ | - | (៤៩,០៥០) |
| សាច់ប្រាក់ក្នុងដៃនិងសាច់ប្រាក់សមមូលដើមគ្រា | | ២,៧៣៤,៧៣៨ | ១០,៩៨៨,១៧៧ | ៩១៨,០៧៨ | ៣,៦៨៨,៨៣៧ |
| **សាច់ប្រាក់ក្នុងដៃនិងសាច់ប្រាក់សមមូលចុងគ្រា** | | **៦៩៤,៨០៧** | **២,៨៣១,៣៣៩** | **២,៧៣៤,៧៣៨** | **១០,៩៨៨,១៧៧** |

# ការិយាល័យកណ្ដាល

០២៣ ៩២២ ១២៦

info@chokchey.com.kh

ផ្ទះលេខ ៩-១១ ផ្លូវវេងស្រេង សង្កាត់ស្ទឹងមានជ័យ ៣ ខណ្ឌមានជ័យ
រាជធានីភ្នំពេញ

www.chokchey.com.kh